វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្ដាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្ដាហ៍នេះ គឺ៖

- កម្ពុជា និងវៀតណាមពិភាក្សាគ្នាអំពីយុទ្ធសាស្ត្រលើកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យទេសចរណ៍
- កូរ៉េខាងត្បូង សន្យានឹងផ្ដល់ជំនួយ ៥០០លានដុល្លារ សម្រាប់ការអភិវឌ្ឍ ប្រទេសឡាវ
- សេដ្ឋកិច្ចអាស៊ីនឹងមានទំហំធំជាងប្រទេសផ្សេងៗទៀតនៅលើពិភពលោកនៅឆ្នាំ២០២០

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះគឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីអោយការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### កម្ពុជា និងវៀតណាម ពិភាក្សាគ្នាអំពីយុទ្ធសាស្ត្រ លើកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យទេសចរណ៍

ក្រសួងទេសចរណ៍កម្ពុជាបានធ្វើដំណើរទៅកាន់ទីក្រុងហូជីមិញ ប្រទេសវៀតណាមកាលពីសប្តាហ៍មុន ដើម្បីចូលរួមពិធីពិព័រណ៍ទេសចរណ៍អន្តរជាតិលើកទី១៥ ក្នុងគោលបំណងផ្សព្វផ្សាយពីគោលដៅទេសចរណ៍របស់ប្រទេសកម្ពុជា។

យោងតាមការផ្សព្វផ្សាយតាមទំព័រហ្វេកប៊ុករបស់ក្រសួងទេសចរណ៍៖ គណៈប្រតិភូកម្ពុជា និងវៀតណាម ក៏បានធ្វើការពិភាក្សាលើកិច្ចព្រមព្រៀងដើម្បីលើកកម្ពស់ទីផ្សារទេសចរណ៍របស់ប្រទេសទាំងពីរអោយទៅជាទិសដៅតែមួយ ក្រោមពាក្យស្លោកមួយថា "ប្រទេសពីរ គោលដៅមួយ"។

យោងតាមប្រសាសន៍ ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍៖ ប្រទេសទាំងពីរបានឯកភាពគ្នាធ្វើកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍សមុទ្រ ជាពិសេសតាមរយៈការប្រើប្រាស់កំពង់ផែសមុទ្រថ្មីនៅក្នុងខេត្តកំពត។ ទេសចរណ៍សមុទ្រត្រូវបានចាត់ទុកជាយន្តការដែលមានប្រសិទ្ធភាពក្នុងការជំរុញកិច្ចសហប្រតិបត្តិការក្នុងចំណោមបណ្តាប្រទេសអាស៊ាន។

កាលពីឆ្នាំមុន ភ្ញៀវទេសចរអន្តរជាតិដែលបានមកទស្សនានៅប្រទេសកម្ពុជាមានចំនួនច្រើន ដែលសម្រេចបាននូវអត្រាកំណើនប្រមាណ១០,៧% ជាមួយនឹងការមកដល់នៃទេសចរអន្តរជាតិជាង៦,២លាននាក់ ក្នុងនោះ ៨០០ ០០០ នាក់ មកពីប្រទេសវៀតណាម។ កម្ពុជាសង្ឃឹមថានឹងអាច

បង្កើនចំនួនភ្ញៀវទេសចរវៀតណាម ទៅដល់មួយលាននាក់ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ខណៈដែលវៀតណាមរំពឹងថានឹងមានទេសចរកម្ពុជាកន្លះលាននាក់ទៅលេងប្រទេសរបស់ខ្លួន។

### តារាងប្រចាំសប្តាហ៍៖ ចំណូលក្នុងស្រុករបស់កម្ពុជាកើនឡើង ១៣% នៅក្នុងត្រីមាសទីមួយក្នុងឆ្នាំ២០១៩

តារាងប្រចាំសប្តាហ៍នេះបង្ហាញថា ការប្រមូលចំណូលក្នុងស្រុកនៅកម្ពុជាបានកើនឡើងដល់ ៤ ៩២៧ប៊ីលានរៀល នៅក្នុងត្រីមាសទី១ឆ្នាំ២០១៩ កើនឡើង១៣,១% ធៀបនឹងអំលុងពេលដូចគ្នាក្នុងឆ្នាំមុន។ ចំណូលពន្ធបានកើនឡើង ៩,២% ខណៈដែលចំណូលមិនមែនពន្ធកើនឡើងដល់ទៅ ៥១,១%។

ក្រុមការងារFACTយើង មិនទាន់ដឹងថា តើអ្វីដែលកំពុងជំរុញឱ្យចំណូលមិនមែនពន្ធមានការកើនឡើងយ៉ាងខ្លាំងនោះទេ ប៉ុន្តែភាគច្រើនប្រហែលជាបណ្តាលមកពីថ្លៃសេវាកម្ម និងចំណូលបានមកពីការលក់ និងជួលទំនិញ។

**ចំណូលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា**

| ប៊ីលានរៀល | ត្រីមាសទីមួយ | | |
|---|---|---|---|
| | 2017 | 2018 | 2019 |
| **ចំណូលក្នុងស្រុក** | **4,310** | **4,358** | **4,927** |
| 1.ចំណូលចរន្ត | 4,292 | 4,345 | 4,896 |
| *ចំណូលពន្ធ* | 3,915 | 3,985 | 4,352 |
| *ចំណូលមិនមែនពន្ធ* | 377 | 360 | 544 |
| 2.ចំណូលមិនមែនពន្ធ | 18 | 13 | 31 |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៩

## ព័ត៌មាន និងនិន្នាការរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### កូរ៉េខាងត្បូង សន្យានឹងផ្តល់ជំនួយ ៥០០លានដុល្លារ សម្រាប់ការអភិវឌ្ឍ ប្រទេសឡាវ

រដ្ឋាភិបាលកូរ៉េខាងត្បូងបានចុះហត្ថលេខា អនុស្សារណៈយោគយល់គ្នាមួយជាមួយប្រទេសឡាវដើម្បីផ្តល់ថវិកាចំនួន ៥០០លានដុល្លារ ដល់គម្រោងអភិវឌ្ឍន៍សម្រាប់រយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ ថវិកាទាំងនេះរកបានតាមរយៈមូលនិធិសហប្រតិបត្តិការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០២០ ដល់២០២៣។

អ្នកដឹកនាំនៃប្រទេសទាំងពីរបានជួបពិភាក្សា និងចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាចំនួន ៣ ទៀត ស្តីពីព័ត៌មាន និងការទំនាក់ទំនងផ្នែកបច្ចេកវិទ្យា, ពាណិជ្ជកម្ម និងកសិកម្ម ដែលបានព្រមព្រៀងដោយមន្ត្រីនៃប្រទេសឡាវ និងកូរ៉េ នៅវិមានប្រធានាធិបតី ទីក្រុងវៀងចន្ទន៍ ក្នុងអំឡុងពេលកិច្ចប្រជុំកំពូលដែលជាផ្នែកមួយនៃដំណើរទស្សនកិច្ចថ្នាក់តំបន់របស់លោកប្រធានាធិបតីមូន។ ក្នុងពេលកិច្ចប្រជុំកំពូលនេះ តំណាងប្រទេសទាំងពីរបានពិភាក្សានូវបញ្ហាជាច្រើន ដែលរួមមានបញ្ហានយោបាយ ការទូត និង សន្តិសុខក្នុងតំបន់ និងអន្តរជាតិផងដែរ។

សាធារណៈរដ្ឋកូរ៉េបានបង្ហាញនូវចក្ខុវិស័យមួយក្នុងការធ្វើសមាហរណកម្មជាមួយបណ្តាប្រទេសមេគង្គមានដូចជា ឡាវ កម្ពុជា មីយ៉ាន់ម៉ា ថៃ និងវៀតណាម ដើម្បីចែករំលែកបទពិសោធន៍ដ៏សំបូរបែបរបស់ខ្លួនជាមួយនឹងការអភិវឌ្ឍនសេដ្ឋកិច្ច ជាពិសេសភូមិកសិកម្ម និងជួយដល់តំបន់ ដើម្បីអោយ ទន្លេហានកាន់តែមានភាពអស្ចារ្យដែលអាចនាំមកនូវប្រយោជន៍ដល់ទន្លេមេគង្គ។

លោកប្រធានាធិបតីមូនក៏បានបង្ហាញក្តីសង្ឃឹមថានឹងមានការពិភាក្សាបន្ថែមនៅឯពិធីសម្ពោធបើកកិច្ចប្រជុំកំពូលកូរ៉េខាងត្បូង-មេគង្គ ដែលនឹងត្រូវធ្វើឡើងនៅទីក្រុងប៊ូសាន ថ្ងៃទី ២៧ ខែវិច្ឆិកា ខាងមុខនេះ។

## សេដ្ឋកិច្ចពិភពលោក

### សេដ្ឋកិច្ចអាស៊ីនឹងមានទំហំធំជាងប្រទេសផ្សេងៗទៀតនៅលើពិភពលោកនៅឆ្នាំ២០២០

សេដ្ឋកិច្ចអាស៊ាននឹងមានទំហំធំជាងសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០២០ ទាក់ទងនឹងភាពស្មើគ្នានៃអំណាចនៃការទិញ

(purchasing power parity)។ ខណៈដែលពិភពលោកកំពុងតែមានជម្លោះពាណិជ្ជកម្ម ហើយប្រឈមនឹងកត្តាប្រជាសាស្ត្រអាស៊ីនៅតែរក្សាបាននូវភាពខ្លាំង និងកំពុងពង្រឹងទំនាក់ទំនងពាណិជ្ជកម្មរបស់ខ្លួនតាមរយៈកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ដូចជា APEC, ASEAN និងអង្គការកិច្ចសហប្រតិបត្តិការសៀងហៃ ជាដើម។

អាស៊ីកំពុងតែមានសមាហរណកម្មសេដ្ឋកិច្ចកាន់តែខ្លាំងជាងមុន ជាមួយនឹងសក្តានុពលផ្នែកទេសចរណ៍ ពាណិជ្ជកម្ម និងវិនិយោគ។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសគម្រោង"ផ្លូវមួយខ្សែក្រវ៉ាត់មួយ"កំពុងតែជំរុញអោយបណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍នៅអាស៊ានរួបរួមគ្នា ដើម្បីឆ្ពោះទៅកាន់ប្រព័ន្ធសេដ្ឋកិច្ចដែលមានលក្ខណៈចម្រុះ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមានៈ តុល្យភាពពាណិជ្ជកម្មសម្រាប់ប្រទេសភាគច្រើននៅក្នុងតំបន់ក៏ដូចជាការសម្រេចចិត្តលើអត្រាការប្រាក់នៅក្នុងប្រទេសថៃ ជប៉ុន ឥណ្ឌូនេស៊ី និងតៃវ៉ាន់។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយៈ

<u>ថ្ងៃច័ន្ទ ទី១៦ ខែកញ្ញា</u>

- ការវិនិយោគលើវិស័យទ្រព្យសម្បត្តិរបស់ចិន សម្រាប់ខែសីហា
- ផលិកម្មឧស្សាហកម្មរបស់ចិន សម្រាប់ខែសីហា
- តុល្យភាពពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី សម្រាប់ខែសីហា
- តុល្យភាពពាណិជ្ជកម្មរបស់ប្រ៊ុយណេ សម្រាប់ខែមិថុនា

<u>ថ្ងៃអង្គារ ទី១៧ ខែកញ្ញា</u>

- តុល្យភាពពាណិជ្ជកម្មរបស់សឹង្ហបុរី សម្រាប់ខែសីហា
- អត្រាភាពគ្មានការងារធ្វើរបស់ហុងកុង សម្រាប់ខែសីហា
- ផលិតកម្មឧស្សាហកម្មរបស់សហរដ្ឋអាមេរិក សម្រាប់ខែសីហា

<u>ថ្ងៃពុធ ទី១៨ ខែកញ្ញា</u>

- តម្លៃនៃការនាំចូល និងនាំចេញរបស់កូរ៉េខាងត្បូង សម្រាប់ខែសីហា
- តុល្យភាពពាណិជ្ជកម្មរបស់ជប៉ុន សម្រាប់ខែសីហា
- ការសម្រេចចិត្តលើអត្រាការប្រាក់របស់ថៃ

<u>ថ្ងៃព្រហស្បត្តិ៍ ទី១៩ ខែកញ្ញា</u>

- ការសម្រេចចិត្តលើអត្រាការប្រាក់បម្រុងរបស់អាមេរិក
- ការសម្រេចចិត្តលើអត្រាការប្រាក់របស់ជប៉ុន
- ការសម្រេចចិត្តលើអត្រាការប្រាក់របស់ឥណ្ឌូនេស៊ី
- ការសម្រេចចិត្តលើអត្រាការប្រាក់របស់តៃវ៉ាន់

<u>ថ្ងៃសុក្រ ទី២០ ខែកញ្ញា</u>

- អត្រាអតិផរណារបស់ជប៉ុន សម្រាប់ខែសីហា
- ការលក់ម៉ូតូរបស់ឥណ្ឌូនេស៊ី សម្រាប់ខែសីហា
- តុល្យភាពពាណិជ្ជកម្មរបស់ថៃ សម្រាប់ខែសីហា
- អត្រាអតិផរណារបស់ហុងកុង សម្រាប់ខែសីហា